# នីតិវិធីដោះស្រាយសំណងសម្រាប់បណ្ណសន្យារ៉ាប់រងរូបិយបណ្ណ

ក្នុងករណីមានឧប្បត្តិហេតុកើតឡើង

↓

លោកអ្នកត្រូវជូនដំណឹងមក **ប្រូសួរ** ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងត្រូវប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់ តាមរយៈ ការជូនដំណឹងដោយផ្ទាល់ ទូរស័ព្ទទាន់ហេតុការណ៍ សារអេឡិចត្រូនិក លិខិតជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀត

↓

**ប្រូសួរ** នឹងតែងតាំងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង

**បាទ/ចាស**

**ប្រូសួរ** នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការតែងតាំងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងទៅកាន់លោកអ្នក

↓

**ប្រូសួរ** នឹងផ្ញើជូនលោកអ្នកនូវទម្រង់បែបបទក្នុងការទាមទារសំណង និងផ្តល់បញ្ជីឯកសារតម្រូវក្នុងរយៈពេល **២៤ ម៉ោង** បន្ទាប់ពីទទួលបានការជូនដំណឹង

↓

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងនឹងទាក់ទងលោកអ្នកដើម្បីស៊ើបអង្កេត វាយតម្លៃការខូចខាតដែលបានកើតឡើង និងស្នើសុំឯកសារពាក់ព័ន្ធផ្សេងៗ

↓

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងនឹងរៀបចំរបាយការណ៍អំពីហានិភ័យដែលបានកើតឡើងសម្រាប់ជាឯកសារមូលដ្ឋានក្នុងការទូទាត់សំណង

**ទេ**

មន្ត្រីដោះស្រាយសំណងរបស់ **ប្រូសួរ** នឹងទៅដល់កន្លែងកើតហេតុដើម្បីស៊ើបអង្កេត និងវាយតម្លៃហានិភ័យដែលបានកើតឡើង

↓

**ប្រូសួរ** នឹងផ្ញើជូនលោកអ្នកនូវទម្រង់បែបបទក្នុងការទាមទារសំណង និងផ្តល់បញ្ជីឯកសារតម្រូវក្នុងរយៈពេល **២៤ ម៉ោង** បន្ទាប់ពីទទួលបានការជូនដំណឹង

↓

អ្នកស៊ើបអង្កេតហានិភ័យរបស់ **ប្រូសួរ** នឹងរៀបចំរបាយការណ៍អំពីហានិភ័យដែលបានកើតឡើងសម្រាប់ជាឯកសារមូលដ្ឋានក្នុងទូទាត់សំណង

↓

ករណីការស្នើសុំទាមទារសំណង មិនមានឯកសារគ្រប់គ្រាន់ **ប្រូសួរ** នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬតាមរយៈសារអេឡិចត្រូនិកទៅកាន់លោកអ្នកក្នុងរយៈពេល **៣ ថ្ងៃ** នៃថ្ងៃធ្វើការ

↓

បន្ទាប់ពីទទួលបានរបាយការណ៍ពីក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង និង/ឬឯកសារគ្រប់គ្រាន់ **ប្រូសួរ** នឹងឆ្លើយតបទៅកាន់លោកអ្នកជាលាយលក្ខណ៍អក្សរអំពីការសម្រេចផ្តល់សំណង ឬការបដិសេធការទទួលខុសត្រូវ ក្នុងរយៈពេល **១៥ ថ្ងៃ** នៃថ្ងៃធ្វើការ

ការសម្រេចផ្តល់សំណង

↓

**ប្រូសួរ** នឹងចេញលិខិតបញ្ជាក់ពីការធ្វើសំណង និងលិខិតបញ្ជាក់ការទាមទារសំណងជូនលោកអ្នកដើម្បីចុះហត្ថលេខាឯកភាពទទួលយកសំណង

↓

**ប្រូសួរ** នឹងទូទាត់សំណងជូនលោកអ្នកក្នុងរយៈពេល **៣ ថ្ងៃ** នៃថ្ងៃធ្វើការ បន្ទាប់ពី លោកអ្នកឯកភាពទទួលយកសំណងចំពោះការទូទាត់ទាំងស្រុង ឬក្នុងរយៈពេល ដូចបានកំណត់នៅក្នុងកិច្ចព្រមព្រៀងទទួលយកសំណងរវាង **ប្រូសួរ** និងអ្នកទាមទារសំណងចំពោះការទូទាត់សំណងជាដំណាក់កាល

ការបដិសេធការទទួលខុសត្រូវ

↓

**ប្រូសួរ** នឹងផ្ញើលិខិតបដិសេធសំណងទៅកាន់អ្នកទាមទារសំណង ដោយបញ្ជាក់អំពីមូលហេតុសម្រាប់ការបដិសេធសំណង

<u>កំណត់សម្គាល់</u>

- ការធានារ៉ាប់រងលើការខូចខាតទ្រព្យសម្បត្តិ៖ មិនមានការជួសជុលណាមួយត្រូវបានអនុញ្ញាតចំពោះទ្រព្យសម្បត្តិដែលបានខូចខាត ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំឡើយ។
- ការធានារ៉ាប់រងលើទំនួលខុសត្រូវ៖ មិនមានការព្រមទទួលខុសត្រូវ ការផ្តល់ជូន ការសន្យា ការធ្វើសំណង ឬការចំណាយណាមួយត្រូវបានធ្វើឡើងក្នុងនាម ឬ ជំនួស លោកអ្នកដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំឡើយ។

## Claim Procedure for MONEY INSURANCE




**Note**

- Insurance on Materials Damages: No repair may be authorized to the damaged items without our prior written consent.
- Liability Insurance: No admission, offer, promise, payment or indemnity shall be made or given by or on behalf of you without our prior written consent.